**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៣

# ប្រកាស
# ស្តីពី
# វិសាមញ្ញការត្រួតពិនិត្យហិរញ្ញវត្ថុ

◆◆◆◆◆◆◆

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី [illegible] ធ្នូ ឆ្នាំ ២០០២

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

C:\2002\finance\prokas



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ០៩៧ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច

-យោងប្រកាសលេខ ២០៤ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ

-យោងប្រកាសលេខ ២៩៩ ប្រក.សហវ.ហ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីសិទ្ធិចុះទិដ្ឋាការលើអាណត្តិបើកប្រាក់

-យោងប្រកាសលេខ ២៩៧ ប្រក.សហវ.ហ.ប្រក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការប្រគល់សិទ្ធិចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

-យោងសារាចរណែនាំលេខ ០០៥ សហវ.ហ សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

-យោងតំរូវការចាំបាច់ក្នុងកិច្ចអនុវត្តការត្រួតពិនិត្យហិរញ្ញវត្ថុតាមផែនការកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ

## ស ំ រេ ច

⁂

ប្រការ១: ត្រូវបានប្រគល់សិទ្ធិជូន :

១-ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច នូវសិទ្ធិចុះទិដ្ឋាការលើលិខិតធានាចំណាយថវិកា និងលើអាណត្តិបើកប្រាក់ក្នុងកំរិតទឹកប្រាក់ចំនួន ១០០លានរៀលចុះ លើកលែងចំណាយ ជំពូក ២០ ជំពូក ៥០ ជំពូក ៥២ ជំពូក ៥៣ និងចំណាយ ជារូបិយប័ណ្ណ ។

២- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនូវសិទ្ធិចុះទិដ្ឋាការលើលិខិតធានាចំណាយថវិកា និងលើអាណត្តិបើកប្រាក់ក្នុងកំរិតទឹកប្រាក់ចំនួន ៥០លានរៀលចុះ លើកលែងចំណាយ ជំពូក ២០ ជំពូក ៥០ ជំពូក ៥២ ជំពូក ៥៣ និងចំណាយជារូបិយប័ណ្ណ ។

ប្រការ២: ត្រូវបានប្រគល់សិទ្ធិអំណាច និងតួនាទីភារកិច្ច ដូចខាងក្រោម :

I - <u>ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច</u> :

I - 1 <u>តួនាទី និងភារកិច្ច</u>

- ប្រតិបត្តិតាមប្រការ២ នៃប្រកាសលេខ ២០៤ សហវ.ថ ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ ។

• ត្រួតពិនិត្យ គ្រប់គ្រង និងទទួលខុសត្រូវក្នុងក្របខ័ណ្ឌអនុវត្តការត្រួតពិនិត្យហិរញ្ញវត្ថុ សំខាន់អំពីយន្តការ និងនីតិវិធីនៃកិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋ ចាត់ចែងរាល់កិច្ចការទាំងឡាយដែលជាបន្ទុករបស់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ព្រមទាំងរៀបចំនូវរបាយការណ៍ត្រួតពិនិត្យជាប្រចាំ គឺ

1- ប្រមូលផ្តុំពត៌មានលើការសន្សំចំណាយ និងការប្រើប្រាស់ឥណទានថវិកា ឱ្យស៊ីសង្វាក់ នឹងកម្មវិធីចំណូល-ចំណាយថវិការដ្ឋប្រចាំត្រីមាស របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

2- ធ្វើរបាយការណ៍រួមស្តីពីស្ថានភាព និងលទ្ធផលនៃកិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋតាមកាលកំណត់ ដោយផ្អែកតាមតួលេខរបាយការណ៍របស់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ។

**I - 2 សិទ្ធិអំណាចក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ :**

ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ចមានសិទ្ធិចុះទិដ្ឋាការ :

• លើលិខិតធានាចំណាយ ឬលើអាណត្តិបើកប្រាក់ដែលបានកំណត់ក្នុងប្រការ ១.១ គឺក្នុងកំរិតទឹកប្រាក់ ១០០លានរៀលចុះ លើកលែងតែចំណាយរបស់ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ "ផ្នែកសន្តិសុខ" និងស្ថាប័នកំពូលទាំង ៥ រួមមាន ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអាជ្ញាធរសវនកម្មជាតិ ។

• មានសិទ្ធិចុះហត្ថលេខាលើប្រកាសធ្វើចលនាឥណទានថវិកា ( និយ័តកម្មថវិកា ) ផ្ទៃក្នុងជំពូក ១១ ចំពោះតែឥណទានថវិកាសំរាប់ចំណាយថ្លៃប្រើប្រាស់ទឹក អគ្គីសនី ទូរស័ព្ទ ក្នុងកំរិតទឹកប្រាក់១០០លានរៀលចុះ ។

**II- លក្ខខ័ណ្ឌទូទៅនៃកិច្ចប្រតិបត្តិការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ :**

**II- 1 សិទ្ធិអំណាចក្នុងកិច្ចប្រតិបត្តិការ :**

• មានសិទ្ធិចុះទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ក្នុងកំរិតទឹកប្រាក់ចំនួន ៥០លានរៀលចុះ ដូចមានចែងក្នុងប្រការ ១.២ ចំពោះសំណើដូចខាងក្រោម :

- ចំណាយរដ្ឋបាលទាំងឡាយណាមានមូលដ្ឋានលើគោលការណ៍ដែលមានស្រាប់ ។
- បៀវត្សនិងប្រាក់បំណាច់លាភការសាធារណៈ "ជំពូក ១០" ដែលមានឯកសារភ្ជាប់តាមស្របច្បាប់អនុញ្ញាត និងមានចុះទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- ថ្លៃឈ្នួលពលករអណ្តែត និងប្រាក់កំរៃភ្នាក់ងារជាប់កិច្ចសន្យាដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- ចំណាយអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ រួមមាន :

១-ចំណាយសង្គមកិច្ចផ្ទាល់ ( ជំពូក ៣១.០១.០១.ពីវាក្យខ័ណ្ឌ ០១ ដល់ ១១ )

២-ចំណាយរាហារូបករណ៍ ( ជំពូក ៣១.០១.០២ ពីវាក្យខ័ណ្ឌ ០១ ដល់ ១៥ )

• តម្រូវឱ្យមានគោលការណ៍ឯកភាពពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន : កម្មវត្ថុចំណាយទាំងឡាយណាដែលស្ថិតក្នុងកំរិតកំណត់នៃការអនុញ្ញាតក្រោម ៥០លានរៀល )

បើគ្មានគោលការណ៍ឬលិខិតបទដ្ឋានជាធរមាន ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកនាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ដើម្បីធ្វើការពិនិត្យដោះស្រាយ ឬលើកយោបល់សុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ មានជាអាទិ :

1- មុខចំណាយទាំងអស់ដូចមានអត្ថន័យចែងក្នុងមាតិកានៃថវិការដ្ឋ ដែលគ្មានបទដ្ឋានចំណាយត្រឹមត្រូវ និងគោលរបបហិរញ្ញវត្ថុជាធរមាន ឬទាក់ទិនដល់ចំណាយរូបិយវត្ថុអន្តរជាតិ ។

2- សោហ៊ុយបេសកកម្មក្រៅប្រទេស

3- ប្រាក់កំរៃលើសម៉ោង

4- ចំណាយចែដន្យដែលមានការចាំបាច់បន្ទាន់

5- ចំណាយសង្គ្រោះបន្ទាន់ ឬគ្រោះធម្មជាតិ

- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទាំងអស់មកនាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច :

ដើម្បីពិនិត្យនិងមានវិធានការសុំយោបល់សម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់សំណើសុំចំណាយ ឬអាណត្តិបើកប្រាក់ ពាក់ព័ន្ធនឹងឥណទានជួសជុល ថែទាំ សំភារៈប្រណិត (គំរោងចំណាយមានទ្រង់ទ្រាយតូចដែលតម្រូវឱ្យប្រើថវិកាជំពូក ១១ ) ឬ សំណើសុំថវិកាជារូបិយវត្ថុអន្តរជាតិ ទោះសំណើសុំចំណាយថវិកាស្ថិតក្នុងក៏រិតកំណត់ប្រគល់សិទ្ធិក្តី (ក្រោម ៥០លានរៀល) ។

**<u>II- 2 តួនាទី និងភារកិច្ច :</u>**

បន្ថែមលើការត្រួតពិនិត្យចំណាយថវិការដ្ឋ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក៏មានកិច្ចការផ្សេងទៀតជំនួយដល់នាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច គឺ :

- ត្រួតពិនិត្យ តាមដាន និង ជំរុញការបង់ចំណូលមិនមែនសារពើពន្ធ ចូលថវិការដ្ឋ
- ចូលរួមកសាងផែនការចំណូល-ចំណាយថវិកាប្រចាំឆ្នាំ រួមទាំងការផ្តល់យោបល់ក្នុងការ ធ្វើនិយ័តកម្មថវិកាផងដែរ តែមិនមានសិទ្ធិធ្វើចលនាឥណទានថវិកាទេ ( ច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុ ត្រង់ជំពូកទី៦ និង អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ត្រង់មាត្រា ២៤) ។
- រាយការណ៍ជាប្រចាំនិងទៀងទាត់អំពីសកម្មភាពការងារ ស្ថានភាពប្រែប្រួលនៃឥណទានថវិកាបានចំណាយ ឬបាតុភាពមិនប្រក្រតីក្នុងកិច្ចប្រតិបត្តិការ នៅរាល់ដំណាច់សប្តាហ៍ ខែ ត្រីមាស ឆមាស ឬ តាមតម្រូវការចាំបាច់បន្ទាន់របស់នាយកដ្ឋាន ។

ប្រការ៣: ត្រូវប្រគល់សិទ្ធិជូនប្រធានក្រសួងចំណាយដែលមានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា (PEAC ) ជាសេនាធិការ សំរេច និង អនុវត្តគំរោងលទ្ធកម្មក្រោមទឹកប្រាក់ចំនួន ៥០លានរៀល ក្នុងមួយគំរោងចំណាយស្របតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈក្រោមសមត្ថកិច្ចណែនាំត្រួតពិនិត្យ ជាប្រចាំដោយនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

C:\2002\finance\prokas

**ប្រការ៤:** មិនអនុញ្ញាតឱ្យមានការសម្របសម្រួលដោយប្រការណាមួយ ដើម្បីបំបែកគំរោងចំណាយនានា ឱ្យទៅជាគំរោងចំណាយតូចៗ ដើម្បីតម្រូវទៅតាមកំរិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិអំណាចឡើយ ។ ប្រការនេះ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនិងក្រសួងចំណាយ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់សវនកម្មជាធរមាន ។

**ប្រការ៥:** ក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង និងស្ថាប័ននានាត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៦:** ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវដឹកនាំក្រុមឱ្យបំពេញតួនាទី និងភារកិច្ចឱ្យបានល្អតាមមុខការបានកំណត់ក្នុងប្រការ៩ នៃប្រកាសលេខ ០៩៧ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ។

**ប្រការ៧:** ក្រៅពីសិទ្ធិប្រគល់ឱ្យចុះទិដ្ឋាការលើលិខិតធានាចំណាយ ឬលើអាណត្តិបើកប្រាក់ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវប្រកាន់ខ្ជាប់នូវសីលធម៌នៃវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ដោយប្រតិបត្តិឱ្យមានប្រសិទ្ធភាពនូវសារាចរណែនាំលេខ ០០៥ សហវ.សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ ។

**ប្រការ៨:** ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសុខាភិបាល គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា *(PEAC)* នៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល មានសិទ្ធិពេញលេញក្នុងការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០៣ តទៅ ។

**ប្រការ៩:** ដោយឡែក ចំពោះក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមបណ្តាក្រសួងដទៃទៀត និងក្រសួង-ស្ថាប័ន ចំណាយទាំងឡាយ ក្រៅពីប្រការ៨ ការប្រគល់សិទ្ធិឱ្យចុះទិដ្ឋាការលើលិខិតធានាចំណាយ ឬ ចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ គឺអាស្រ័យដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ១០:** ក្នុងពេលអនុវត្តប្រកាសនេះ ប្រសិនបើមានជួបការលំបាកដោយប្រការណាមួយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចនឹងអញ្ជើញមកទាក់ទងផ្ទាល់ ឬតាមលិខិតស្នាមផ្ញើមកនាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ដើម្បីពិនិត្យដោះស្រាយ ឬលើកយោបល់សុំការណែនាំពីថ្នាក់ដឹកនាំក្រសួង ។

**ប្រការ១១:** រាល់បទបញ្ញត្តិដែលបានចែងក្នុងប្រកាសលេខ ២៩៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦ និងប្រកាសលេខ ២៥៧ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៧ ហើយដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១២:** អគ្គលេខាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ប្រធានរតនាគារជាតិ ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា និង ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសុខាភិបាល ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីជូនជ្រាបជាពត៌មាន "
-ក្រសួងអប់រំ យុវជន និងកីឡា
-ក្រសួងសុខាភិបាល
" ដើម្បីសហការអនុវត្តន៍ "
-គ្រប់អង្គភាពពាក់ព័ន្ធដូចប្រការ១២ " ដើម្បីមុខការ "
-គ្រប់ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល
-មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគ្រប់ក្រុម
" ដើម្បីជ្រាបជាពត៌មាន "
-ឯកសារនិងកាលប្បវត្តិ